# មេរៀនទី ៤២៖ ព្រះអង្គប្រទានទឹក

និក្ខមនំ ១៧៖១-៧

**មេរៀន** *( យូធូបលីង )*៖ https://youtu.be/Dh6ZC-zOcTI

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/_vN0KwALjvg

**គោលបំណង៖** ព្រះអង្គអត់ធ្មត់ ហើយព្រះអង្គចង់ឲ្យប្អូនៗចេះអត់ធ្មត់

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១៤៥៖៨** *"ព្រះយេហូវ៉ាទ្រង់ប្រកបដោយមេត្តាករុណា និងអាណិតអាសូរ ទ្រង់យឺតនឹងខ្ញាល់ ក៏មានសេចក្តីសប្បុរសដ៏ធំទូលាយ"*។

**ចំរៀង** *( យូធូបលីង )*៖

១. តើអ្នកណាជាម្ចាស់នៃខ្ញុំ https://youtu.be/e4gCJBfWNTs

២. សរសើរព្រះយេស៊ូវ https://youtu.be/uA448Ncse8Q

៣. ក្តីស្រឡាញ់នៃព្រះផ្អែមហើយអស្ចារ្យ https://youtu.be/W7hfRd0undE

## ១. អធិស្ឋាន

## ២. ចំរៀង

## ៣. ល្បែងកំសាន្ត «រក្សាភាពស្ងៀមស្ងាត់»



១. បែងចែកកុមារជាក្រុមដែលមានគ្នាពី៥ទៅ៦នាក់។

២. គោលបំណងនៃល្បែងនេះគឺនៅស្ងៀមស្ងាត់ ដោយមិនបញ្ចេញសំលេងអ្វីទាំងអស់( សូម្បីតែក្អកក៏មិនបានដែរ! )។

៣. នៅពេលដល់គ្រូចាប់ផ្តើមកំណត់ម៉ោងថា នឹងត្រូវចាប់ផ្តើមលេង ឲ្យកុមារគ្រប់គ្នាត្រូវ នៅឲ្យស្ងៀម។

៤. ក្រុមដែលអាចរក្សាភាពស្ងៀមស្ងាត់បានយូរ ជាងគេជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមរំលឹកកុមារទាំងអស់ពីសារៈសំខាន់ នៃការអត់ធ្មត់ ទោះបីជានៅពេលដែលយើងភ័យខ្លាចក៏ដោយ។

## ៤. ការណែនាំមេរៀន

នៅពេលដែលយើងអាចរង់ចាំអ្វីមួយដោយមិនខឹង មិនភ័យខ្លាច ឬមិនត្អូញត្អែរនោះ យើងហៅវាថាជាការអត់ធ្មត់។ វាមិនមែនជារឿងងាយស្រួលនោះទេក្នុងការអត់ធ្មត់ នៅពេលដែលយើងចង់ធ្វើឲ្យអ្វីមួយ កើតឡើង ឬក៏ចង់បញ្ឈប់អ្វីមួយមិនឲ្យកើតឡើង។ យើងចង់ធ្វើអ្វីឲ្យបានភ្លាមៗ។ សព្វថ្ងៃនេះមនុស្សជាច្រើនមានការលំបាកក្នុងការអត់ធ្មត់ណាស់ ប៉ុន្តែព្រះតែងតែអត់ធ្មត់ជាមួយយើង ក៏ដូចជាព្រះអង្គរង់ចាំយើងនៅដែលទ្រង់ប្រាប់ឲ្យយើងធ្វើមួយ។ ព្រះអង្គអត់ធ្មត់ពេលដែលយើងភ្លេចទុកចិត្តទ្រង់។ ព្រះអង្គអត់ធ្មត់នៅពេលដែលយើងមិនស្តាប់បង្គាប់ទ្រង់ ទោះបីជាមនុស្សរអ៊ូរទាំនិងទ្រង់ក៏ដោយ តែព្រះនៅអត់ធ្មត់ជាមួយ

និងពួកគេ។ ព្រះអង្គរង់ចាំដោយការអត់ធ្មត់ និងអត់ទោសឲ្យយើងហើយទ្រង់បង្រៀន យើងឲ្យទុកចិត្តទ្រង់ និងស្តាប់បង្គាប់ទ្រង់ដោយក្តីស្រលាញ់។ សូមស្វែងយល់បន្ថែមទៀតអំពីការអត់ធ្មត់របស់ព្រះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅពេលដែលជនជាតិអ៊ីស្រាអែលត្អូញត្អែរពីអាហារបរិភោគ ព្រះបានប្រទាននូវនំម៉ាណា និងសត្វគ្រួចឲ្យពួកគេ។ តាមពិតទៅពួកគេទទួលបាននំម៉ាណារៀងរាល់ព្រឹក ហើយសត្វគ្រួចរៀងរាល់ល្ងាច ប៉ុន្តែថ្ងៃមួយពួកគេមិនអាចរកទឹកផឹកបាន។ តើអ្នកគិតថា ជនជាតិអ៊ីស្រាអែលនឹកចាំទេថាព្រះមានអំណាចប៉ុនណា? ហើយតើពួកគេទុកចិត្តថាព្រះនឹងប្រទានទឹក ឲ្យពួកគេផឹកដូចដែលទ្រង់បានប្រទាននំម៉ាណា និងសត្វគ្រួចឲ្យពួកគេដែរឬទេ។

តែជំនួសឲ្យការទុកចិត្តព្រះ ពួកគេបានតែត្អូញត្អែរទៅកាន់ម៉ូសេ ដោយនិយាយថា ពួកគេ នឹងត្រូវស្លាប់នៅវាលខ្សាច់នេះ ដោយការស្រេកទឹក។ ម៉ូសេខឹងនឹង ជនជាតិអ៊ីស្រាអែលជាខ្លាំង ពីព្រោះពួកគេតែងតែត្អូញត្អែរ និងបំភ្លេចអ្វីដែលព្រះបានធ្វើចំពោះពួកគេ។

ទោះបីជាយ៉ាងណាក៏ព្រះនៅតែ បង្ហាញពីក្តីស្រលាញ់ និងការអត់ធ្មត់របស់ព្រះអង្គជានិច្ច។ ជំនួសឲ្យការខឹងជនជាតិអ៊ីស្រាអែល ព្រះអង្គ បានប្រទានទឹកឲ្យពួកគេផឹកទៅវិញ។ ព្រះអង្គបានមានបន្ទូលប្រាប់ម៉ូសេឲ្យយកដំបងទៅវាយដុំថ្ម ហើយ នៅពេលដែលម៉ូសេធ្វើតាម ក៏មានទឹកចេញពីថ្មនោះមែន! ទោះបីជាពេលខ្លះ មនុស្សបានភ្លេចព្រះនិង ភ្លេចពីអំណាចរបស់ព្រះហើយត្អូញត្អែរក៏ដោយ ក៏ព្រះនៅតែអត់ធ្មត់ និងមើលថែពួកគេយ៉ាងល្អ!

## ៦. សំនួរពិភាក្សា

១. តើជនជាតិអ៊ីស្រាអែលត្អូញត្អែរពីអ្វី? (*ខ្វះទឹកផឹក*)

២. តើពួកគេត្អូញត្អែរដាក់អ្នកណា? (*ដាក់ម៉ូសេ*)

៣. តើជនជាតិអ៊ីស្រាអែលគួរតែធ្វើអ្វីជំនួសឲ្យការត្អូញត្អែរ? (*ទុកចិត្តព្រះថាព្រះនឹងប្រទានទឹកដល់ ពួកគេដូចដែលព្រះបានប្រទាននំម៉ាណានិងសត្វគ្រួចឲ្យពួកគេអញ្ចឹងដែរពីព្រោះគេបាន ឃើញការអស្ចារ្យនៅពេលដែលពួកគេអត់មានអាហារ*)

៤. តើព្រះប្រទានទឹកឲ្យពួកគេដោយរបៀបណា? (*ម៉ូសេប្រើដំបងគាត់វាយដុំថ្ម ហើយទឹកក៏ចេញពី ដុំថ្មនោះ*)

៥. តើព្រះនឹងធ្វើអ្វីខ្លះសំរាប់ប្អូនប្រសិនបើប្អូនភ្លេចព្រះ និងភ្លេចពីអំណាចរបស់ព្រះ? (*ព្រះអង្គតែងតែអត់ធ្មត់ជាមួយប្អូនហើយទ្រង់នៅតែយកចិត្តទុកដាក់មើលថែប្អូនជាដរាប*)

៦. តើប្អូននិងធ្វើអ្វីនៅពេលដែលប្អូនមានបញ្ហា និងត្រូវការអ្វីមួយ? (*ទុកឲ្យកុមារឆ្លើយ*)

## ៧. ល្បែងកំសាន្ត

**ជម្រើសទី១៖ "ការចងចាំ"**






១. ថតចម្លងរូបភាព "ការចងចាំ" ដែលមាននៅទំព័រខាងក្រោម ហើយចែកកុមារជាក្រុមៗ ដោយក្នុង មួយក្រុមៗមានគ្នាពី៣-៤នាក់។

២. ឲ្យពេលកុមារ១នាទីដើម្បីមើលរូបភាពនេះ។ ប្រាប់កុមារឲ្យព្យាយាមយកចិត្តទុកដាក់ មើលអ្វីដែលមាន នៅក្នុងរូប នេះតាមដែលពួកគេអាចធ្វើបាន។

៣.មួយនាទីក្រោយមក ឲ្យកុមារផ្គាប់ក្រដាសហើយសួរសំនួរ។ ក្រុមដែលអាចឆ្លើយសំនួរបានច្រើនជាងគេគឺជាអ្នកឈ្នះ។

ក. សំណួរៈ

- តើមានសត្វអូដ្ឋប៉ុន្មានក្បាលនៅទីនោះ?(*៣ក្បាល*)
- តើក្រណាត់ដែលនៅលើខ្នងសត្វអូដ្ឋមានពណ៌អ្វីខ្លះ?(*ពណ៌ក្រហម និងបៃតង*)
- តើមានសត្វផ្សេងទៀតដែរឬទេនៅទីនោះ? (*មានសត្វចៀម និងពពែ*)

៤.រំលឹកកុមារថាយើងងាយនឹងភ្លេចលឿនណាស់ពីរូបភាពដែលយើងបានឃើញ យើងតែងតែភ្លេចជាញឹកញាប់ថាព្រះអង្គស្រលាញ់យើង ហើយព្រះអង្គមានអំណាចគ្រប់គ្រាន់ដើម្បីមើលថែយើង។ ចូរចាំថាព្រះតែងតែអត់ធ្មត់ ទោះបីជាយើងត្អូញត្អែរ ហើយភ្លេចព្រះអង្គក៏ដោយ ក៏ព្រះនៅតែស្រលាញ់យើងដែរ!

**ជម្រើសទី២ៈ «សូមឲ្យទឹកមកពួកយើង»**



១. នាំសិស្សចេញមកខាងក្រៅថ្នាក់រៀន

២. ចាក់ទឹកចូលក្នុងថង់ប្លាស្ទិក

៣. យកថង់ទឹកនោះទៅព្យួរនៅលើដើមឈើ (ឬព្យួរកន្លែងណាក៏បានឲ្យតែអាចព្យួរបាន)

៤.ចែកកុមារជា២ក្រុម ហើយឲ្យក្រុមនីមួយៗប៉ាវក្រុមណាឈ្នះត្រូវ លេងមុន

៥.បិទភ្នែកកុមារតំណាងក្រុមអ្នកឈ្នះនោះ ហើយបង្វិលគាត់ឲ្យគ្រប់៣ជុំ បន្ទាប់មកឲ្យដំបងវែងមួយទៅគាត់ ដើម្បីវាយបំបែកថង់ទឹកនោះគាត់មានឳកាស ៣ដង ក្នុងការវាយបំបែកថង់នោះ។

## ៨. ខគម្ពីរចងចាំ

**ទំនុកដំកើង ១៤៥ៈ៨** *"ព្រះយេហូវ៉ាទ្រង់ប្រកបដោយមេត្តាករុណា នឹងអាណិតអាសូរទ្រង់យឺតនឹងខ្ញាល់ ក៏មានសេចក្តីសប្បុរសដ៏ធំទូលាយ"*។

## ៩. ចំរៀង

(សូមរើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)

## ១០. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ទំនាក់ទំនងជាមួយព្រះយេស៊ូវគឺនាំការអត់ទោសឲ្យយើង តែមិនមែនជាការគ្រប់លក្ខណ៍ទេ។ ដូចជាសេចក្តីជំនឿយើងដែលបានរីកចំរើននៅក្នុងព្រះយេស៊ូវ យើងកាន់តែដូចជាទ្រង់! យើងគួរតែអរព្រះគុណព្រះយេស៊ូវ ដែលទ្រង់អត់ធ្មត់ជាមួយយើង ហើយបង្កើតរូបយើងដូចជារូបអង្គទ្រង់។ ទោះបីជាមនុស្សមួយចំនួនធ្វើឲ្យ យើងខកចិត្តយើងនៅតែអាចបង្ហាញក្តីស្រលាញ់ទៅកាន់ពួកគេដូចជា ព្រះអង្គបានបង្ហាញក្តីស្រលាញ់ របស់ទ្រង់ពេលដែលយើងធ្វើខុសអីចឹងដែរ។ ទូលសូមព្រះឲ្យជួយអ្នកក្នុងការស្រលាញ់ និងមើលថែក្មេងៗ ដែលអ្នកនឹងបង្រៀនថ្ងៃនេះ។

